ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# អូរឡង់
## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

ឈ្មោះសហគមន៍នេសាទ ៖ អូរឡង់
ភូមិ ៖ អូរឡង់
ឃុំ ៖ សៀមបូក
ស្រុក ៖ សៀមបូក
ខេត្ត ៖ ស្ទឹងត្រែង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ អូរឡង់ រយៈពេល ៣ ឆ្នាំ( ២០២០ - ២០២២ )

| | |
|---|---|
| សហគមន៍នេសាទ | ៖ អូរឡង់ |
| ភូមិ | ៖ អូរឡង់ |
| ឃុំ | ៖ សៀមបូក |
| ស្រុក | ៖ ៖ សៀមបូក |
| ខេត្ត | ៖ ស្ទឹងត្រែង |

ខែមករា ឆ្នាំ២០១៩

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ........ ២

ក.ប្រជាពលរដ្ឋ ........ ២

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៤

ឃ.ធនធានជលផល ........ ៤

ឃ.១.ប្រភេទត្រី៖ ........ ៤

ឃ.២.ប្រភេទវារីសត្វ៖ ........ ៤

ឃ.៣.ប្រភេទសត្វបក្សី ........ ៤

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៥

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៦

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនវិស័យ ........ ៦

ខ. គោលបំណងរួម ........ ៦

គ.គោលបំណងជាក់លាក់ ........ ៦

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៦

ឃ.១.ធនធានជលផល និងអេកូឡូស៊ី ........ ៦

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៦

ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ........ ៧

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ៧

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៨

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៨

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ........ ៨

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ៩

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........ ១០

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ........ ១០
ឃ.៣. ការងារគ្រប់គ្រង ........ ១០
ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........ ១០
ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........ ១១
ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........ ១១
ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១១
ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១២
ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១២
ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖ ........ ១២
ច.យុទ្ធសាស្ត្រ ........ ១៣
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូរឡង់ រយៈពេល៣ឆ្នាំ ( ២០២០ ដល់ ២០២២ )** ........ ១៤
**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ( ២០២០- ២០២២ )** ........ ១៩

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទអូរឡង់ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ១៩៩៧ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដែលមានរយៈពេល៣ឆ្នាំ គឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទនេះ មានទីតាំងស្ថិតនៅក្នុងភូមិអូរឡង់ ឃុំសៀមបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន ២២៥គ្រួសារ ស្មើនឹង៣៦០នាក់ ស្រីចំនួន១២៤ នាក់ និងមានគណៈកម្មការចំនួន០៧ នាក់ ស្រីចំនួន០២ នាក់។ សហគមន៍នេសាទអូរឡង់ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមកសហគមន៍នេសាទបានអនុវត្តសកម្មភាពសំខាន់ៗ រួមមានដូចជាការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ រៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ ចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងៗព្រមទាំងចុះល្បាតក្នុងកន្លែងនេសាទសហគមន៍ជាប្រចាំ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទនៅជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺៈ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមានការកាប់បំផ្លាញព្រៃលិចទឹក នាំឱ្យបាត់បង់ព្រៃលិចទឹកជាច្រើន ត្រីថយចុះគ្រប់ប្រភេទត្រី ការនេសាទនៅរដូវត្រីពងកូន បាក់ច្រាំងមាត់ទន្លេ និងកំណើនអ្នកនេសាទមកពីក្រៅសហគមន៍នេសាទ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត កំណើនប្រជាពលរដ្ឋ ខ្វះប្រភពទឹកធ្វើស្រែ ខ្វះចំណេះដឹង និងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ការដាំដំណាំ តម្លៃផល ផលិតផលមិនស្ថិតស្ថេរ និងទីផ្សារនៅឆ្ងាយពីភូមិ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមាន ការប្រើឧបករណ៍នេសាទខុសច្បាប់ (ឧបករណ៍ឆក់ ដាក់ដាយ) ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស មិនមានការលើកទឹកចិត្តដល់គណកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ជលផល លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ សមាជិកសហគមន៍យល់ថាការងាររបស់គណៈកម្មាការជាតួនាទីរបស់បុរស ចំណែកស្ត្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីមានស្ត្រីច្រើនចូលរួមក្នុងកិច្ចប្រជុំនានា ប៉ុន្តែការសម្រេចចិត្តរបស់ស្ត្រីនៅមានកម្រិត ។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋក្នុងភូមិអូរឡង់សរុប ១,១៦៨នាក់ ស្ត្រី ៦០៤នាក់ ស្មើនឹងចំនួន ៣០៩គ្រួសារ និងខ្នងផ្ទះចំនួន ៣០៨ ខ្នងផ្ទះ ក្នុងនោះមានជនជាតិខ្មែរ ៤៥% រួមនឹងជនជាតដើមភាគតិចកួយចំនួន១៧០គ្រួសារ ស្មើហ្នឹង៥៥% ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ១០០%។

ប្រជាពលរដ្ឋក្នុងភូមិអូរឡង់ មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីមេម៉ាយមាន ១០នាក់
- ចំនួនពោះម៉ាយមាន ០៦ នាក់
- ចំនួនជនពិការមានប្រុស៧នាក់ ស្ត្រី ០៥ នាក់
- ចំនួនចាស់ជរាមានប្រុស០៤ នាក់ ស្ត្រី ០៨នាក់
- ចំនួនអ្នកមានជម្ងឺរាំរ៉ៃមាន ០៤ នាក់ ស្ត្រី ០៣នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន៨៨៤ នាក់ ស្ត្រី៤៤៩ នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន២៥៣ នាក់ ស្ត្រី១៣៦ នាក់ និងកម្រិតអនុវិទ្យាល័យចំនួនសរុប៣១ នាក់ស្ត្រី១៩ នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន ៣០៩គ្រួសារ ត្រូវនឹង១០០%
- ធ្វើស្រែចំនួន២៩៤ គ្រួសារ ដែលមានទំហំដីចំនួនសរុប ៤៤១ ហិកតា
- ដាំបន្លែជាលក្ខណៈគ្រួសារចំនួន១០ គ្រួសារ / ដែលមានទំហំ (៥០ម៉ែត្រ) ហិកតា
- ជាងផ្ទះចំនួន ០២ គ្រួសារ
- ធ្វើចំការចំនួន២៨៤ គ្រួសារ ដែលមានទំហំដីចំនួនសរុប៨៥២ ហិកតា(ស្រូវ ពោត ចន្ទីរ សណ្តែក ល្ង ត្រសក់..... ទៅតាមរដូវកាល)
- លក់ដូរចំនួន ១៤ គ្រួសារ
- ជាងធ្វើទូក ០១ នាក់
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ១០០%
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួនសរុប១៥ គ្រួសារ (ធ្វើផ្អក ប្រហុក ត្រីប្រៃ ដែលមានចំនួនពី៥គីឡូក្រាមទៅ១០ គីឡូក្រាមក្នុងមួយឆ្នាំ
- ពេទ្យឆ្មប ០៣នាក់។

## ៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក.ទីតាំង

កន្លែងនេសាទសហគមន៍អូរឡង់ ជាដែននេសាទសាធារណៈរបស់រដ្ឋ។ កន្លែងនេសាទសហគមន៍អូរឡង់មានទំហំ ៨៩០ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់៖**

- ខាងជើងទល់នឹង ព្រំប្រទល់សហគមន៍នេសាទភូមិសៀមបូក ឃុំសៀមបូក ស្រុកសៀមបូក

- ខាងត្បូងទល់នឹង  អូរគ្រាក ព្រំប្រទល់នៃខេត្តក្រចេះ
- ខាងកើតទល់នឹង   ព្រំប្រទល់សហគមន៍នេសាទភូមិកោះជ្រឹម ឃុំអូរម្រះ ស្រុកសៀមបូក
- ខាងលិចទល់នឹង ភូមិអូរឡង់ ឃុំសៀបូក ស្រុកសៀមបូក ខេត្តស្ទឹងត្រែង

ខ.ដែននេសាទ

កន្លែងសហគមន៍នេសាទអូរឡង់ មានវិសាលភាពនៅក្នុងទន្លេមេគង្គ មានអូរចំនួន១១ កោះចំនួន០៤ និងអន្លង់ចំនួន ០៤ អន្លង់។

**ខ.១.ទន្លេមេគង្គ**

| ឈ្មោះទន្លេ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៨.៥០០ | ពេញមួយឆ្នាំ |

**ខ.២.អូរ**

| ឈ្មោះប្រឡាយ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| អូរអញ្ចោង | ៥.០០០ | នេសាទបានក្នុងខែវស្សា |
| អូរខ្មោច | ១៥.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរឡង់ | ៥៩០.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរសណ្តាន់ | ៤.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរជ្រៅ | ៤.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរឈ្លីក | ៤៥.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរស្អំ | ២៨០ | នេសាទមិនបាន |
| អូរយាយនួន | ១.៥០០ | នេសាទបានក្នុងរដូវវស្សា |
| អូរនាម | ១០.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរស្រស់ | ១៤.០០០ | នេសាទបានក្នុងរដូវវស្សា |
| អូរគ្រាក | ១០០.០០០ | នេសាទបានក្នុងរដូវវស្សា |

**ខ.៣.កោះ**

| ឈ្មោះកោះ | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះព្រាលធំ | ៣០០ × ១៥០០ | ៤៥០ |
| កោះព្រាង | ៧០ × ៣០០ | ២១ |
| កោះផ្កាវ | ១០០ × ៤០០ | ៤០ |
| កោះបាយសំនុំ | ១៥០ × ១០០០ | ១៥០ |

**ខ.៤.អន្លង់**

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | ទំហំសរុប (ហិកតា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់អូរអញ្ចោង | ប: ១០០ × ទ: ១០០ | ១ | ១៥ | ០៩ |
| អន្លង់កែងជ្រៃ | ប: ៣៥០ × ទ:៣៥០ | ១២.២៥ | ១៦ | ១០ |
| អន្លង់ថ្មធំ | ប: ៣៥០ × ទ:៣៥០ | ១២.២៥ | ១៤ | ០៧ |
| អន្លង់អូរឈ្លើក | ប: ៣៥០ × ទ:៣៥០ | ១២.២៥ | ១៤ | ០៧ |

**គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន០១អន្លង់ គឺអន្លង់អូរឈ្លើក តាមការសម្រេចរបស់សន្និបាតសហគមន៍នេសាទអូរឡង់។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ ( ម៉ែត្រ) | ទំហំសរុប (ហិកតា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់អូរឈ្លើក | ៣៥០ម×៣៥០ | ១២.២៥ | ១៤ | ០៧ |

**ឃ.ធនធានជលផល**

**ឃ.១.ប្រភេទត្រី**

ត្រីរ៉ស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង កំភ្លាញ ឆ្លូញ ខ្មាន់ ឆ្អិន ច្រកែង កន្ទ្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ច្រូក កាហែរ ត្រីលេញ ទ្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឫស្សី ត្រីខ្ចឹង ត្រីខ្យា ត្រីកេះ ឆ្តោក ត្រីកែ ត្រីត្រសក់ ត្រីគល់រាំង ត្រីអណ្តែង ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីឆ្មា ត្រីរាហ៊ូ ត្រីក្របី ត្រីឫសចេក ត្រីក្អុក ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីខ្យាថ្ម ត្រីប៉ាសុីអុី ត្រីប៉ាវ៉ា ត្រីអាចម៍កុក។

**ឃ.២.ប្រភេទវារីសត្វ៖**

ក្តាម ខ្យង ខ្ចៅ គ្រុម លៀស អណ្តើក កន្ធាយ ពស់ កំពិស កង្កែប ហ៊ីង គីង្គក់។

**ឃ.៣.ប្រភេទបក្សី៖**

កុកស កុកក្រក មាន់ទឹក មាន់ ប្រវឹក ទាព្រៃ រនាលខ្យង ក្រសារ ខ្លាត្រី ក្អែកទឹក ក្អែកគោក។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ដើមត្រែង ដើមអញ្ចោង ដើមរំចេក ដើមអណ្តែង ដើមត្រស់ ដើមរាំង ដើមល្វា ដើមផ្កាទឹក ដើមព្រុះទឹក ដើមបន្លាឃ្លេ។

**៤.ការធ្វើនេសាទ**

**ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២២៥គ្រួសារ ស្មើ៤៥០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន ៨៤គ្រួសារ ស្មើ១៦៨នាក់

- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ១៥ នាក់ ស្រី០៦នាក់។

**ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍នេសាទ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| សន្ទូចរនង | ផ្លែ | ២០០គ្រួសារ× ១០០ផ្លែ= ២០.០០០ ផ្លែ | ៥០គ្រួសារ× ១០០ផ្លែ=៥.០០០ផ្លែ | ៥គ្រួសារ× ២០០ផ្លែ= ១.០០០ផ្លែ | ផ្លែលេខ១២ ដល់០៥ | ផ្លែលេខ១២ ដល់០៥ | ផ្លែលេខ១២ ដល់០៥ | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ២០០គ្រួសារ x២=៤០០វង់ | ៨៧គ្រួសារ× ១វង់=៨៧វង់ | ០៥គ្រួសារ x២=១០វង់ | សំរុង៣,៥០ -៥,៥០ម | សំរុង៣,៥០ - ៥,៥០ម | សំរុង៣,៥០ - ៥,៥០ម | ពេញមួយឆ្នាំ |
| ចាន់ | គ្រឿង | ៦០គ្រួសារ×៥ គ្រឿង=៣០០ គ្រឿង | ២០គ្រួសារ ×៣គ្រឿង= ៦០គ្រឿង | គ្មាន | មុខកាត់០,៣ ម បណ្ដោយ ៦០ស.ម | មុខកាត់០,៣ ម បណ្ដោយ ៦០ស.ម | គ្មាន | ខែ៨-១១ |
| លប | គ្រឿង | ៦០គ្រួសារx៥ គ្រឿង=៣០០ គ្រឿង | ១០គ្រួសារ ×៣គ្រឿង= ៣០គ្រឿង | គ្មាន | មុខកាត់០,៣ ម បណ្ដោយ ១,៥០ម | មុខកាត់០,៣ មបណ្ដោយ ១,៥០ម | | ខែ៨-១១ |
| ទ្រូ | គ្រឿង | ២០គ្រួសាx ២=៤០ គ្រឿង | គ្មាន | គ្មាន | មុខកាត់៤ស.មប្រវែង១ម | គ្មាន | គ្មាន | ខែ៨-១១ |
| សៃយ៉ឺន | គ្រឿង | ២០គ្រួសារx ២=៤០ គ្រឿង | ៥គ្រួសារ× ២គ្រឿង= ១០ គ្រឿង | គ្មាន | មុខកាត់១,៧ ០ម បណ្ដោយ ២ម | មុខកាត់១,៧ ០មបណ្ដោយ ២ម | គ្មាន | ខែ៨-១១ |
| ឈ្នាងជញ្ជាត់ | គ្រឿង | ២០គ្រួសារx ២=៤០ គ្រឿង | គ្មាន | គ្មាន | ទំហំ០,៣- ០,៥មប្រវែង ១ម | គ្មាន | គ្មាន | ខែ៧-១២ |

ប្រភេទកាណូត

| ប្រភេទទូកកាណូត | ចំនួន | | | ចំណុះ (គីឡូក្រាម) | | | កម្លាំងសេះ | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេរវជាប់ម៉ាស៊ីនហុងដា | ១៤៥ | ៥ | ២០ | ១០០-៣០០ | ១០០-៣០០ | ១០០-៣០០ | ៥,៥-៧-១៣ | ៥,៥-៧-១៣ | ៨,១៣ |

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសារ | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |
| សរុប | | | ១.៦៦១,០៥ |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ក.ទស្សនៈវិស័យ

សហគមន៍នេសាទអូរឡង់មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ខ.គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនៈវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹក ក្នុងរដូវជំនឡើង ដាំព្រៃលិចទឹកឡើងវិញ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធាន ជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

### ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១.ធនធានជលផល និងអេកូឡូស៊ី

### ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺគិតគូរអំពីប្រភេទឧបករណ៍នៅក្នុងដែននេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងទន្លេមេគង្គកន្លែងនេសាទសហគមន៍អូរឡង់ | នេសាទពេញ១ឆ្នាំជាលក្ខណៈគ្រួសារ | សំណាញ់ | ជម្រៅ៣-៥ម ក្រឡា២-១២ហ៊ុន | ២វង់/គ្រួសារ | សមាជិកសហគមន៍អ្នកនេសាទ |
| | | លប | មុខកាត់០,៨០ម×១,៥ម | ៥គ្រឿង/គ្រួសារ | |
| | | ចាន់ | មុខកាត់៣០-៥០ស.ម ប្រវែង១ម | ៥គ្រឿង/គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| | | សៃយ៉ឺន | មុខកាត់១,៧ម បណ្តោយ២,៥ម | ២គ្រឿង/គ្រួសារ | ខាងក្នុង និង អ្នកនេសាទខាងក្រៅសហគមន៍ |
| | | ទ្រូ | មុខកាត់៤០ស.ម ប្រវែង១ម | ២គ្រឿង/គ្រួសារ | |
| | | ឈ្នាងជញ្ជាត់ | មុខកាត់១,៥ស.ម ប្រវែង២ម | ២គ្រឿង/គ្រួសារ | |
| | | សន្ទូចរនង | ផ្លែលេខ២០ ដល់០៥ | ១០០ផ្លែ/គ្រួសារ | |
| -អូរអញ្ចែង<br>-អូរខ្មោច -អូរឡង់<br>-អូរជ្រៅ -អូរសណ្តាន់<br>-អូរឈើក -អូររនាម<br>-អូរយាយនួន<br>-អូរស្រស់ -អូរគ្រាក | ខែ៨ - ខែ១២ | សន្ទូចរនង | ផ្លែលេខ២០ ដល់០៥ | ១០០ផ្លែ/គ្រួសារ | សមាជិកសហគមន៍នេសាទទន្សោង |
| | | សំណាញ់ | ជម្រៅ៣-៥ម ក្រឡា២-១២ហ៊ុន | ២វង់/គ្រួសារ | |
| | | លប | មុខកាត់០,៨០ម×១,៥ម | ៥គ្រឿង/គ្រួសារ | |
| | | ចាន់ | មុខកាត់៣០-៥០ស.ម ប្រវែង១ម | ៥គ្រឿង/គ្រួសារ | |
| | | សៃយ៉ឺន | មុខកាត់១,៧ម បណ្តោយ២,៥ម | ២គ្រឿង/គ្រួសារ | |
| | | ទ្រូ | មុខកាត់៤០ស.ម ប្រវែង១ម | ២គ្រឿង/គ្រួសារ | |

**ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ**

ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍ភូមិអូរឡង់ | បង្គោលព្រំធ្វើពីស៊ីម៉ង់ត៍ចំនួន ១០បង្គោល | - លាងសម្អាតបង្គោលព្រំចាស់<br>- ទិញថ្នាំ រៀបចំក្រុមចុះលាប<br>- ផ្សព្វផ្សាយជាធារណៈ | ៦០០ | គណៈកម្មការ សមាជិក មេភូមិ | ២០២០ | ២០២០ |
| | ផ្ទាំងប៉ាណូផែនទីធ្វើពីដែកចំនួន ៣ ផ្ទាំង | ផលិត និងបោះផ្ទាំងប៉ាណូ | ៤៤០ | គណៈកម្មការ | ២០២០ | ២០២០ |
| | ស្លាកអប់រំ ៣០ | ផលិតស្លាកអប់រំចុះបោះស្លាកតាមសហគមន៍ និងតាមទន្លេ | ១២០ | គណៈកម្មការ | ២០២០ | ២០២០ |

**ឃ.១.៣.ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស**

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សត្រូវបានរៀបចំដូចខាងក្រោមៈ

| ឈ្មោះ | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់អូរឈើក | ១២,២៥ ហិកតា | ត្រីមេពូជ សត្វស្លាប ព្រៃលិចទឹកគ្រប់ | -ផ្សព្វផ្សាយពីកន្លែងអភិរក្ស<br>-បោះទង់សំគាល់ព្រំតំបន់អភិរក្ស ចំនួន០៤បង្គោល<br>-ដាក់ផ្លាកសញ្ញាសម្គាល់ចំនួន៣០<br>-ចុះល្បាតការពារជាប្រចាំ | ៥១០ | ២០២០ | ២០២២ |

ឃ.១.៤.ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| នៅក្នុងដែនសហគមន៍នេសាទភូមិអូរឡង់ | តាមមាត់ទន្លេ និងតាមមាត់អូរតាមភូមិ | ព្រៃលិចទឹកចម្រុះ | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ៤០០ | ២០២០ | ២០២២ |

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ

ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំឡើងដូចខាងក្រោម

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទពូជ | ប៉ាន់ប្រមាណថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ៥គ្រួសារចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្ដុះបណ្ដាលចិញ្ចឹមមាន់តាមបច្ចេកទេសជាក្ខណៈគ្រួសារ<br>-អនុវត្តជាក់ស្ដែងជាមួយគ្រួសារកសិករធ្វើទ្រុង ផ្ដល់ពូជចិញ្ចឹម<br>-តាមដានត្រួតពិនិត្យជាប្រចាំ | ពូជក្នុងស្រុក ១គ្រួសារ ទទួលបានមាន់១០ក្បាល សរុប ១៥០ក្បាល | ៧៥០ | ២០២០ | ២០២២ |
| ៥គ្រួសារបង្កើតធនាគារក្របី | -ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បង្កើតគោលការណ៍ក្រុម<br>-ជ្រើសរើសគ្រួសារ និងផ្ដល់មេក្របី<br>-តាមដានត្រួតពិនិត្យការថែទាំ | ២ក្បាល/គ្រួសារ | ២.០០០ | ២០២០ | ២០២២ |
| ១៥គ្រួសារចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | -ប្រជុំផ្សព្វផ្សាយ ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>-បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹម<br>-រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>-តាមដានត្រួតពិនិត្យការថែទាំ | កូនជ្រូកពូជ៣០ក្បាល | ៣.០០០ | ២០២០ | ២០២២ |
| ដាំបន្លែតាមបច្ចេកទេស | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត | គ្រាប់បន្លែ (ស្ពៃ គ្រប់ | ៧៥០ | ២០២០ | ២០២២ |

| | | | | | |
|---|---|---|---|---|---|
| កសិកម្មវៃឆ្លាតចំនួន ៣០គ្រួសារ | -វគ្គបណ្តុះបណ្តាលបច្ចេកទេសដាំបន្លែ<br>-ផ្តល់គ្រាប់ពូជបន្លែ<br>-តាមដានត្រួតពិនិត្យ | ត្រកួន ត្រសក់ សណ្តែកគួរ | | | |
| បង្កើតក្រុមសន្សំប្រាក់ (សមាជិក១៥នាក់) | -ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ<br>-រៀបចំបោះឆ្នោតរើស គណៈកម្មការ<br>-រៀបចំលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>-បណ្តុះបណ្តាលគណៈកម្មការក្រុម<br>-ប្រជុំបូកសរុបប្រាក់សន្សំប្រចាំខែ<br>-ត្រួតពិនិត្យតាមដានជាប្រចាំ | | ១.០០០ | ២០២០ | ២០២២ |
| បណ្តុះផ្សិតចំបើងចំនួន ១០គ្រួសារ | -ជ្រើសរើសគ្រួសារកសិករស្ម័គ្រចិត្ត<br>-បណ្តុះបណ្តាលបច្ចេកទេសបណ្តុះផ្សិត ធ្វើមេផ្សិត អនុវត្តផ្ទាល់<br>-តាមដានត្រួតពិនិត្យ | ផ្សិតចំបើង | ៣.០០០ | ២០២០ | ២០២២ |
| រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍ | -ផ្សព្វផ្សាយពីគោលបំណងគម្រោង<br>-សិក្សាប៉ាន់ប្រមាណអ្នកប្រើប្រាស់<br>-ជ្រើសរើសគណៈកម្មការគ្រប់គ្រង<br>-បង្កើតគោលការណ៍ប្រើប្រាស់<br>-បណ្តុះបណ្តាលបច្ចេកទេស<br>-រៀបចំប្រព័ន្ធទឹកស្អាត<br>-តាមដានត្រួតពិនិត្យ | រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍ | ២០.០០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណកូនត្រី | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ (៥គ្រួសារ/ឆ្នាំ) | -ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>-រៀបចំស្រះ ដាក់កូនត្រី<br>-បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី<br>-ត្រួតពិនិត្យ ធ្វើសំណាក | ៥ស្រះទំហំ ៨ម×៧ម | ៨០០ក្បាល ក្នុង១គ្រួសារ | ៣.០០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| សាងសង់អណ្តូងស្នប់ចំនួន៥អណ្តូង | ២.៥០០ | ២០២០ | ២០២២ |
| សាងសង់បង្គប់អនាម័យក្នុងសហគមន៍ចំនួន៥០គ្រួសារ | ៣.០០០ | ២០២០ | ២០២២ |
| បង្កើតឡជីវឧស្ម័នដល់សមាជិកសហគមន៍ ៥គ្រួសារ | ២.០០០ | ២០២០ | ២០២២ |
| ផ្តល់ធុងចម្រោះទឹក ចំនួន១០០ធុង | ២.៥០០ | ២០២០ | ២០២២ |

### ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់ និងការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការ | ៧០០ | ២០២០ | ២០២២ | |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | | | | |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | | | | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ និងចងក្រងបណ្តាញក្រុមទ្រទ្រង់ | | | | |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | | | | |

### ឃ.៣.ការងារគ្រប់គ្រង

### ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណ ថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | ៣ដង/១ខែ | ១.០៨០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/១ខែ | ៤.៥០០ | ២០២០ | ២០២២ |
| ទិញទូកស្នាច់ និងម៉ាស៊ីន (១៣សេះ) | ១ គ្រឿង | ១.២០០ | ២០២០ | ២០២២ |
| ប្រេងសម្រាប់ចុះល្បាត | ៥០លីត្រ/ខែ | ១.៨០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ | ១ កន្លែង | ៥០០ | ២០២០ | ២០២២ |

### ឃ.៣.២.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ត្រូវរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ១២ដង | ៣៨០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ១២ដង | ៣៨០ | | |
| បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា | ១ដង | ២៥០ | | |
| បណ្ដុះបណ្ដាលសរសេរគម្រោងសំណើរ | ១ដង | ២៥០ | | |
| ទស្សនៈកិច្ចសិក្សាក្រៅខេត្តផ្លាស់ប្ដូរបទពិសោធន៍ | ១ដង | ១.០០០ | | |

### ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សាមជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២ដង/ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២ដង/ឆ្នាំ | ៦០០ | | |
| ផ្សព្វផ្សាយច្បាប់ស្ដីពីជលផល បទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២ដង/ឆ្នាំ | ៦០០ | | |
| យុទ្ធនាការផ្សព្វផ្សាយ ប្រមូលឧបករណ៍នេសាទខុសច្បាប់ និងដុតបំផ្លាញ | ១ដង/ឆ្នាំ | ១៥០ | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | ១ដង/ឆ្នាំ | ៦០០ | | |

### ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣០០ | ២០២០ | ២០២២ | -គណៈកម្មាការសហគមន៍នេសាទ<br>-អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | ២០២០ | ២០២២ | |

### ឃ.៣.៥.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព៥០០៛ | ២០២០ | ២០២២ | ៤៥ | |
| ភាគទានប្រចាំឆ្នាំពីសមាជិក | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំចំនួន ២.០០០/គ្រួសារ នៃសមាជិកសរុប | ២០២០ | ២០២២ | ៣៣៧,៥០ (៣ឆ្នាំ) | |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅចំនួន៨៥នាក់ (៣០.០០០ រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ១.៩១២ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសាចំនួន១៥នាក់ (៥០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៥៦២,៥០ | |
| បុណ្យផ្កាសាមគ្គី | រៀបចំពិធីបុណ្យផ្កាសាមគ្គីទូទាំងភូមិអូរឡង់ដើម្បីយកថវិកាជួយដល់ការងារសហគមន៍នេសាទ | ២០២០ | ២០២២ | | |
| បដិភាគពីក្រុមសន្សំប្រាក់ | បានភាគលាភរាល់ចុងឆ្នាំ | ២០២០ | ២០២២ | | |
| **សរុបថវិការបស់សហគមន៍** | | | | **២.៨៥៧** | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែន រដ្ឋាភិបាល និងអំណោយពីសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | **៦១.០៣៣** | |
| **សរុបថវិកាចំណាយ** | | | | **៦៣.៨៩០** | |

### ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច និងអ្នកពាក់ព័ន្ធ | ៣០០ | ២០២០ | ២០២២ | -គណៈកម្មការ<br>-អាជ្ញាធរឃុំ |

ច.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍អូរឡោចរយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.១.ធនធានជលផល និងអេកូឡូស៊ី | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំ ពេលវេលា និងទីកន្លែងនេសាទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០០<br>១ដង×១០០×២លើក×៣ឆ្នាំ | សហគមន៍នេសាទ<br>រដ្ឋបាលជលផល<br>អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ជួសជុលបង្គោលព្រំចាស់ និងលាងសម្អាតបង្គោលចំនួន១០បង្គោល និងជំរះស្មៅជុំវិញ និងលាបថ្នាំថ្មីឡើងវិញ | - បង្គោលព្រំចំនួន៥ដើម ត្រូវបានជួសជុល និងបង្គោលចំនួន៥ ដើមត្រូវបានសម្អាត និងលាបថ្នាំថ្មីឡើងវិញ<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៥០០ | រដ្ឋបាលជលផល<br>អង្គការនានា<br>សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទី និងរូបភាពផ្សព្វផ្សាយចំនួន២ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន២ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ៥០០ | | ២០២០ | ២០២០ | |
| | ផលិតស្លាកអប់រំដាក់នៅក្នុងសហគមន៍ និងតាមដងទន្លេ | ស្លាកអប់រំចំនួន៣០ត្រូវបានផលិត និងបានបោះនៅតាមសហគមន៍/តាមទន្លេ | ១២០ | | ២០២០ | ២០២០ | |
| ឃ.១.៣.ការកំណត់និងរៀបចំតំបន់អភិរក្សអន្លង់អូរល្ពីក | - ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍កន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ស្លាកនៅតំបន់អភិរក្ស៣០ស្លាក<br>- ចុះល្បាតការពារជាប្រចាំ | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់កន្លែងអភិរក្ស និងចូលអភិរក្សទាំងអស់គ្នាក្នុងសហគមន៍។ | ១.៤៨០ | រដ្ឋបាលជលផល<br>អង្គការនានា<br>សប្បុរសជន | ២០២០ | ២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រងការពារព្រៃលិចទឹក | - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក | ព្រៃលិចទឹកកើនឡើងវិញធនធានត្រីមានការកើនឡើងវិញ | ៤០០ | រដ្ឋបាលជលផល<br>អង្គការនានា<br>សប្បុរសជន | ២០២០ | ២០២២ | |

| គោលផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | - ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | | | | | | |
| ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់ ចំនួន៥គ្រួសារ | ៧៥០ | រដ្ឋបាលជលផល<br>អង្គការដៃគូ | ២០២០ | ២០២២ | |
| | បង្កើតក្រុមសន្សំប្រាក់(សមាជិក១៥នាក់) | មានសមាជិកចូលរួមចំនួន១៥នាក់ | ១.០០០ | | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូកចំនួន១៥គ្រួសារ | ៣.០០០ | | ២០២០ | ២០២២ | |
| | ដាំបន្លែជាលក្ខណៈគ្រួសារ | មានគ្រួសារដាំបន្លែចំនួន៣០ គ្រួសារ | ៧៥០ | | ២០២០ | ២០២២ | |
| | រៀបចំធនាគារក្របីក្នុងសហគមន៍ | មានសមាជិកចូលរួមចំនួន១០ គ្រួសារ | ២.០០០ | | ២០២០ | ២០២២ | |
| | បណ្តុះផ្សិតចំបើងលក្ខណៈគ្រួសារ | មានគ្រួសារបណ្តុះផ្សិតចំនួន១០គ្រួសារ | ៣.០០០ | | ២០២០ | ២០២២ | |
| | រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍ | មានសមាជិកចូលរួមចំនួន៥០គ្រួសារ | ២០.០០០ | | ២០២០ | ២០២២ | |
| ឃ.២.២. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងចំនួន៥គ្រួសារ | ៣.០០០ | | ២០២០ | ២០២២ | |
| ឃ.២.៣. ផែនការសេវាសហគមន៍និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច | បង្កើតឡជីវឧស្ម័នដល់សមាជិក | ឡជីវឧស្ម័នចំនួន៥ឡសម្រាប់៥គ្រួសារ | ២.៥០០ | រដ្ឋបាលជលផល<br>អង្គការនានា<br>សប្បុរសជន | ២០២០ | ២០២២ | |
| | សាងសង់បង្គន់អនាម័យ | មានបង្គន់អនាម័យចំនួន៥០បង្គន់ | ៣.០០០ | | ២០២០ | ២០២២ | |
| | សាងសង់អណ្តូងស្នប់ | មានអណ្តូងស្នប់ ៥អណ្តូង | ២.០០០ | | ២០២០ | ២០២២ | |
| | ផ្តល់ធុងចម្រោះទឹក | មានធុងចម្រោះចំនួន១០០ធុង | ២.៥០០ | | ២០២០ | ២០២២ | |
| ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការ | គណៈកម្មការ និងសមាជិកមានការយល់ដឹងពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងរបៀបបង្ការ | ១០០ | រដ្ឋបាលជលផល<br>អង្គការនានា<br>សប្បុរសជន | ២០២០ | ២០២២ | |

| គោលផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | មានបង្គោលវាស់កំពស់ទឹកចំនួន១ | ២០០ | | ២០២០ | ២០២២ | |
| | កំណត់ រៀបចំទីទួលសុវត្ថិភាព | មានកន្លែងទីទួលសុវត្ថភាពចំនួន១ | ១០០ | | ២០២០ | ២០២២ | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ និងចងក្រងជាបណ្តាញ | មានគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ និងបានចងក្រងបណ្តាញ | ១០០ | | ២០២០ | ២០២២ | |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | គណៈកម្មការមានចំណេះដឹងទាក់ទង និងការបន្សាំការប្រែប្រួលអាកាសធាតុ | ២០០ | | ២០២០ | ២០២២ | |
| ឃ.៣. ការងារគ្រប់គ្រង | | | | | | | |
| ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | បានចុះល្បាត៣ដង/ខែ | ១.០៨០ | រដ្ឋបាលជលផល | ២០២០ | ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | បានចុះល្បាត២ដង/១ខែសហការជាមួយអាជ្ញាធរមូលដ្ឋាន | ៤.៥០០ | អង្គការនានា សប្បុរសជន | ២០២០ | ២០២២ | |
| | ទិញទូកស្នាច់ម៉ាស៊ីន (១៣សេះ) | មានទូកម៉ាស៊ីន ចំនួន១គ្រឿង | ១.២០០ | | ២០២០ | ២០២២ | |
| | ប្រេងសម្រាប់ចុះល្បាត | ៥០លីត្រ/១ខែ | ១.៨០០ | | ២០២០ | ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | មានស្នាក់ការ១ខ្នងសម្រាប់សហគមន៍នេសាទធ្វើការងារ | ៥០០ | | ២០២០ | ២០២២ | |
| ឃ.៣.២. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ១ដង/១ខែ ជាមួយគណៈកម្មការ សមាជិកក្នុងសហគមន៍ | ៣៤០ | អង្គការដៃគូ រដ្ឋបាលជលផល | ២០២០ | ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយក្រុមឃុំ | ចូលរួម១ដង/១ខែជាមួយក្រុមប្រឹក្សាឃុំ | ៣៤០ | អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | -មានវគ្គបណ្តុះបណ្តាលលើមុខជំនាញនីមួយៗ១លើក/១ឆ្នាំ<br>-សមត្ថភាពសហគមន៍នេសាទបានល្អ | ២៥០ | សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលការសរសេរគម្រោងសំណើ | | ២៥០ | | ២០២០ | ២០២២ | |
| | ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | គណៈកម្មការទទួលបាននូវចំនេះដឹង និងបទពិសោធន៍ល្អ | ៣.០០០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀង | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ជលផលច្បាប់និងបទដ្ឋាន បច្ចេកទេសពាក់ព័ន្ធ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល និងការប្រមូល ឧបករណ៍នេសាទខុសច្បាប់ ដុតបំផ្លាញ | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ១៥០ | | ២០២០ | ២០២២ | |
| | ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍ នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ៣០០ | | ២០២០ | ២០២២ | |
| ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | -បានផ្សព្វផ្សាយ ២ដង/ឆ្នាំ<br>-បានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់សហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | ២០២០ | ២០២២ | |
| ឃ.៣.៥.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | ភាគទានពីសមាជិកភាព | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព ៥០០៛ /នាក់ | | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |
| | ភាគទានពីសមាជិកប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ១ឆ្នាំម្តង ២,០០០៛/គ្រួសារ | | | ២០២០ | ២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិន | បានទទួលប្រាក់បដិភាគពីអ្នកនេសាទ | | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | មែនជាសមាជិកសហគមន៍នេសាទ | មកពីខាងក្រៅ៥០,០០០/ទូក/ថ្ងៃ | | | | | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ | | | ២០២០ | ២០២២ | |
| | បុណ្យផ្កាសាមគ្គី | សហគមន៍បានថវិកាមួយចំនួនពីបុណ្យ ផ្កាសាមគ្គីដើម្បីយកមកបម្រើការងារអភិរក្សធនធានជលផលក្នុងសហគមន៍ | | | ២០២០ | ២០២២ | |
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | | | ២០២០ | ២០២២ | |
| ង.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពី ស្ត្រី ជនជាតិដើមភាគតិច និងជនជាតិភាគតិច | -បានប្រជុំមហាសន្និបាត ១ដង/ឆ្នាំ<br>-ធ្វើសេចក្ដីរាយការណ៍ពីលទ្ធផលការងារ និងលើកផែនការបន្ត | ៣០០ | អង្គការដៃគូ រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |

## តារាងកម្មវិធីការងារ ចាំឆ្នាំ (២០២០ ដល់ ២០២២)

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ឃ.១. ធនធានជលផល និងអេកូឡូស៊ី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | × | | | | | | × | | | | | | × | | | | | | × | | | | | | × | | | | | | × | | | | | |
| ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ជួសជុលបង្គោលព្រំ៥បង្គោល | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សម្អាតបង្គោលព្រំចំនួន៥បង្គោល | | | | | | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីស/ហ នេសាទចំនួន២ផ្ទាំង | | | | | | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ស្លាកអប់រំដាក់នៅសហគមន៍ | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ឃ.១.៣.ផែនការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់អូរឈ្លីក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍ | | | | | | | × | | | | | | | × | | | | | | | × | | | | | | × | | | | | | × | | | |
| ដាក់ទង់សម្គាល់កន្លែងអភិរក្ស និងដាក់ស្លាកសញ្ញា | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ឃ.១.៤. ផែនការគ្រប់គ្រង ការពារព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ផ្សព្វផ្សាយអោយបានទូលំទូលាយពីសារៈប្រយោជន៍ | | | | | × | | | | | | | | × | | | | | | × | | | | | | × | | | | | × | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹកចំនួន២០ស្លាក | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | |
| បង្កើតក្រុមសន្សំប្រាក់១ក្រុម | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | | | | | × | × | | | | | | | | | | | | × | × | | | | | | | | | |
| រៀបចំសួនបន្លែតាមលក្ខណៈគ្រួសារ | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | × | × |
| បង្កើតធនាគារក្របីក្នុងស/ហ | | | | | | × | × | × | | | | | | | | | | | | | | | | | | | × | × | | | | | | | | |
| បណ្តុះផ្សិតចំបើងលក្ខណៈគ្រួសារចំនួន១០គ្រួសារ | | | | | | | | × | × | × | | | | | | | | | | × | × | × | | | | | | | | | | × | × | × | | |
| រៀបចំប្រព័ន្ធទឹកស្អាតក្នុងសហគមន៍នេសាទ | | | | | | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | |
| **ឃ.២.២ ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះលក្ខណៈគ្រួសារ | | | | | | | | × | × | × | × | × | × | | | | | | | × | × | × | × | × | × | | | | | | × | × | × | × | × | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| បង្កើតឡជីវឧស្ម័នដល់សមាជិកចំនួន៥គ្រួសារ | | | | | | × | × | × | × | | | | | | | | | | | | | × | × | × | × | × | × | | | | | | × | × | × | × |
| សាងសង់បង្គន់អនាម័យ | | | | × | × | × | | | | | | | | | | | | | × | × | × | | | | | | | | × | × | × | × | | | | |
| សាងសង់អណ្តូងស្នប់ | | | | | | | | | | | × | × | × | | | | | | | | | | | | | | | × | × | × | × | × | × | × | × | × |
| ផ្តល់ធុងចម្រោះទឹក១០០ធុង | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | |
| **ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការផ្សេងៗ | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំបង្គោលវាស់កម្ពស់ទឹក | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| កំណត់រៀបចំទីទួលសុវត្ថិភាព | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តភូមិនិងចងក្រងជាបណ្តាញ | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | | | | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយខ្លួនឯង | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចុះល្បាតដោយសហការជា | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| មួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ទិញទូកស្មាច់ម៉ាស៊ីន | | | × | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រេងសម្រាប់ល្បាត | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ | | | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បណ្តុះបណ្តាលអំពីការគ្រប់គ្រងថវិកា | | | | | | | | | | | × | | | | | | | | | × | | | | | | | | | | × | | | | | | |
| បណ្តុះបណ្តាលអំពីរបៀបសរសេរគម្រោងសំណើ | | | | | | | | | | | | | | | | | | | | | | | | | × | | | | | | | | | | | |
| ទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ | | | | | | | | × | | | | | | | | | | | | | | | | | | | | | | × | | | | | | |
| **ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀង | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ផ្សព្វផ្សាយច្បាប់ជលផលនិងបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល និងចុះប្រមូលឧបករ ណ៍នេសាទខុសច្បាប់ ដុតបំផ្លាញចោល | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| ប្រជុំផ្សព្វផ្សាយអំពីតួនាទីរបស់បុរសស្ត្រីក្នុងសហគមន៍នេសាទ និងការងារផ្ទះ សមភាពនិងសមធម៌យេនឌ័រ | | | | | | | × | | | | | | | | | | | | | × | | | | | | | | | × | | | | | | | |
| **ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន សន្និបាតប្រចាំឆ្នាំ | | | × | | | | | | | | | × | | | | | | | | | × | | | | | | | | × | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | | | | | | | × | × | × | | | | | | | | | | | × | × | × | | | | | | | | | × | × | × |
| **ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិក | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ភាគទានប្រចាំឆ្នាំ | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | |
| ប្រាក់បដិភាគអ្នកនេសាទខាង | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ក្រៅសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រាក់បដិភាគអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បុណ្យផ្កាសាមគ្គី | | | | | | | × | | | | | | | | | | | | × | | | | | | | | | | | × | | | | | | |
| ប្រាក់ចំណូលពីប្រភពផ្សេងៗ (ជំនួយពីរាជរដ្ឋាភិបាលជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងពីសប្បុរសជន) | | | | × | | | | | | | | | | | × | | | | | | | × | | | | | | | | × | | | | | | |
| **ង. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ | | | | × | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |

លេខ......33 ខឡ
បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ......05......ខែ..12....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង,ថ្ងៃទី..05...ខែ..12.......ឆ្នាំ២០១៩
ជ- នាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់

លេខ០៦.........
បានឃើញ និងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ.........ខែ.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមបូក,ថ្ងៃទី..១៦...ខែ..តុលា....ឆ្នាំ២០១៩
មេឃុំសៀមបូក

ឆិ សារី

សូមគោរពជូន
លោកមេឃុំសៀមបូក
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ.........ខែ.....ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ភូមិអូរឡង់,ថ្ងៃទី..16...ខែ..តុលា....ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទអូរឡង់

លេខ.........................

បានឃើញ និងគោរពជូន

លោកប្រធាន

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង

"ដើម្បីពិនិត្យ និងសម្រួល"

ថ្ងៃ..........................ខែ................ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ស្ទឹងត្រែង,ថ្ងៃទី.......ខែ..........ឆ្នាំ២០១៩

**នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង**

**ទុំ នីរ៉ូ**

លេខ.........................

បានឃើញ និងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

"ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"

ថ្ងៃ..........................ខែ................ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ស្ទឹងត្រែង,ថ្ងៃទី.......ខែ..........ឆ្នាំ២០១៩

ប្រធាន

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង**

**លៀង-សេង**

លេខ.........................

បានឃើញ និងឯកភាព

ថ្ងៃ..........................ខែ................ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី.......ខែ.......ឆ្នាំ២០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**ខ ជាសាន**